ការទទួលខុសត្រូវ

ការទទួលខុសត្រូវ

របបនៅភ្នំពេញសព្វថ្ងៃ ហាក់បីដូចជាយក ស្ថាប័នព្រះមហាក្សត្រ ជាផ្សៀសំអាង ដើម្បីលាបមុខមាត់ខ្លួនឲស្រស់ល្អ ឬ ជាសំឡាញ (ទឹងមោង) ទុកជា ធម្មានុរូប នៃរបប សំរាប់ការពារនូវអំពើគ្រប់បែបយ៉ាង ដែលខ្លួននឹង ធ្វើបន្តែ ដើម្បី រក្សាអំណាច។ ទង្វើនេះ គឺជា ការបញ្ចូល នៃស្ថាប័នព្រះមហាក្សត្រ ឲចូលរួមទាំងស្រុក នៅក្នុង អភិក្រម នៃការពង្រឹង របបផ្តាច់ការ។ ទោះបីមាន ការបង្ខំ ឬមិនបង្ខំក្តី ស្ថាប័នព្រះមហាក្សត្រ រួមបញ្ចូលខ្លួន ជាមួយគណបក្សកាន់អំណាច ក្នុងការប្រព្រឹត្តិ នៃអំពើអកុសលទាំងឡាយ ដែលនាំ បំផ្លាញប្រជាជាតិ។ ដើម្បីថ្វាយជា អំណោយ ដល់ព្រះមហាក្សត្រ ក្នុងការចូលរួមនេះ, គណបក្សកាន់អំណាច រួមនឹង គណបក្សហ្ជុនស៊ីនប៊ីច គេនាំគ្នា ធ្វើវិសោធនកម្ម រដ្ឋធម្មនុញ្ញ បញ្ចូលច្បាប់បន្ថែម[1] សំរាប់ការពារអង្គព្រះមហាក្សត្រ កុំឲ នរណា អាច រិះគន់ ឬ ដាក់កំហុស តាមយោបល់មតិបាន ដល់ព្រះអង្គ។ តាមការពិត ច្បាប់បន្ថែមនេះ បើពិនិត្យឲច្បាស់ គឺគេធ្វើឡើង មិនមែន សំរាប់ ការពារ អង្គ

[1] រដ្ឋធម្មនុញ្ញបច្ចុប្បន្ន នៅក្នុង ជំពូកទី២ មាត្រា ៧ បដិញ្ញាត ថា អង្គព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបានឡើយ។

ការទទួលខុសត្រូវ

ព្រះមហាក្សត្រនោះទេ ផ្ទុយទៅវិញ វាសំរាប់ការពារ នូវគ្រប់ការ បំពានច្បាប់ទាំងឡាយ របស់ពួកអ្នកផ្តាច់ការ ដែលពួកគេ យកអង្គព្រះមហាក្សត្រ ជាសំឡាញ។ ជាធម្មតា យន្តការ នៃការ បន្ទំ របស់ពួកនោះ វាគ្មានអ្វី ពិបាកនឹងយល់សោះ ព្រោះ ពួក នោះ គេមានធាតុជា អកុសលទាំងស្រុង។ ដូច្នេះ អកុសល មិន អាចផ្តល់ នូវអ្វីឲបានល្អនោះឡើយ។ ទុកណាជា ពួកនោះ ខំ លើក អង្គព្រះមហាក្សត្រ ដាក់លើ បូជនីយវេទី ធ្វើពីមាស់ក៏ ដោយ តែគេយកវេទីនោះ ទៅដាក់នៅទីកន្លែង មានពោរពាស ដោយលាមក។ ម្យ៉ាងទៀត ច្បាប់នោះ មិនអាចការពារ អង្គព្រះ មហាក្សត្របានទេ ព្រោះវាកើតចេញពី ស្ថាប័ន ខុសច្បាប់ ដូច្នេះ ដើម្បី អនុវត្តវាបាន មានតែប្រើមធ្យោបាយ ហិង្សា ឬ ប្រើតុលាការ រណបពួកខ្លួនតែប៉ុណ្ណោះ។ តែដោយសារ នៅស្រុក ខ្មែរ យោងតាម រដ្ឋធម្មនុញ្ញ មិនអាចមានម្ចាស់អំណាចពីរ នាក់បាន ដូច្នេះ ប្រជាពលរដ្ឋខ្មែរ ជាម្ចាស់អំណាចផ្តាច់មុខ។ ដូច្នោះ វាបញ្ជាក់ថា មានតែប្រជាពលរដ្ឋប៉ុណ្ណោះទេ ដែលមាន អំណាចផ្តល់ នូវ ការការពារបន្ថែម ថ្វាយដល់ អង្គព្រះមហា ក្សត្រ តាមប្រជាមតិ។ កំណែទម្រង់ រដ្ឋធម្មនុញ្ញ តាមរយៈ សភា ជាតិ ស្តីពី អង្គព្រះមហាក្សត្រ វាមិនគ្រប់គ្រាន់នោះឡើយ ហើយ នៅក្នុង ករណី នៃ សភាជាតិ អធម្មនុញ្ញ សព្វថ្ងៃ, វិសោធនកម្ម ដែលកំពុងធ្វើ វាគឺជា ច្បាប់អធម្មនុញ្ញ សុទ្ធសាធ។

ការទទួលខុសត្រូវ

រាហាក់បីដូចជា ព្រះមហាក្សត្រខ្មែរ ទ្រង់កំពុងដើរតួ ជា ស្ម័គ្រចិត្ត អ្នកមួយផង ជា អ្នករងគ្រោះផង។ តែល្បែងនេះ មិនអាចហួតនូវការទទួលខុសត្រូវ របស់ព្រះអង្គ ជា ព្រះមហាក្សត្របានឡើយ យោងតាម មាត្រា ៨ នៃរដ្ឋធម្មនុញ្ញ[2] ព្រោះព្រះអង្គ ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ។ ទោះបី អង្គ ព្រះមហាក្សត្រ មិនអាចនរណារំលោភបំពានបាន តែព្រះអង្គ មិនអាចស្ថិតនៅលើ សិទ្ធិ និង សេរីភាព របស់ព្រះជាពលរដ្ឋខ្មែរ បាននោះឡើយ ព្រោះរាជាណាចក្រកម្ពុជា ទទួលស្គាល់ សិទ្ធិ មនុស្ស ដូចមានចែងក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ និង សេចក្តីប្រកាសជាសាកល ស្តីពីសិទ្ធិមនុស្ស និង កតិសញ្ញា ព្រមទាំង អនុសញ្ញាទាំងឡាយទាក់ទងទៅនឹង សិទ្ធិមនុស្ស សិទ្ធិ នារី និងសិទ្ធិកុមារ។ ក្នុង ករណីនេះ បើសិនជា ព្រះអង្គ យល់ ព្រម ចុះព្រះរាជហត្ថលេខា លើច្បាប់ថ្មីនោះ ព្រះអង្គនឹងបង្ហាញ ជាថ្មីម្តងទៀត នូវធាតុព្រះអង្គ ជាស្តេច រណបអំណាចផ្តាច់ការ និង ស្តេច បង់ពាក្យសត្យ។ រាជបំណងចង់រក្សា រាជានិយម ក្នុង លក្ខខណ្ឌ អាក្រក់បែបនេះ វាគ្រាន់តែជា ការរក្សា គ្មាន ប្រយោជន៍អ្វី ដល់ប្រជាជាតិ និង រាជានិយមនោះឡើយ។ ប្រវត្តិ សាស្ត្រ ច្បាស់ជា ចារទុក នូវរជ្ជកាលព្រះអង្គ ថាជា អកុសលដាច់ ខាត សំរាប់ប្រជាជាតិ។ ប្រហែលព្រះអង្គ មានព្រះរាជហទ័យថា

---

[2] មាត្រា ៨ វគ្គទី២ បដិញ្ញាត ថា ព្រះមហាក្សត្រ ទ្រង់ជាអ្នកធានាឯកភាពជាតិ អធិបតេយ្យ និង បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ ជាអ្នកធានាការគោរពសិទ្ធិ និង សេរីភាពរបស់ប្រជាពលរដ្ឋ និង ការគោរពសន្ធិសញ្ញាអន្តរជាតិ។

ការទទួលខុសត្រូវ

ព្រះអង្គជា ជនរងគ្រោះម្នាក់ដែរ ក្នុងចំណោម ជនដទៃទៀត នៃ របបផ្តាច់ការនៅស្រុកខ្មែរ តែទ្រង់ ត្រូវយល់ឃើញថា ស្ថាប័ន ព្រះមហាក្សត្រ គឺជាផ្នែកមួយដ៏សំខាន់ នៃរបបផ្តាច់ការ ហើយ គេ យកមកប្រើ ជាឧបករណ៍មួយ ដើម្បី បម្រើជា អាវុធច្បាប់ នៃការបង្ក្រាប ដល់ប្រជាពលរដ្ឋខ្មែរ ដែលទ្រង់ ជាអ្នកធានា ការគោរព សិទ្ធិ និង សេរីភាព និង បំរើប្រយោជន៍ យៀកណាម ដែលទ្រង់ ជាអ្នកធានា ឯករាជ្យជាតិ អធិបតេយ្យ និង បូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

ព្រះអង្គមិនអាច ចាត់ទុកខ្លួន ជាជនរងគ្រោះបានទេ ព្រោះ ទ្រង់ ជាភាគីរួមចំណែក ពេញលេញ។ ដូច្នេះ ជាថ្នីម្តងទៀត, ត្រូវ ព្រះអង្គ ប្រុងប្រយ័ត្ន ! អកុសល ដែលបានបង្កឡើង ហើយ ក្រោ បសង្កត់ទៅលើប្រជាជាតិ, វាមិនអាចរត់គេចខ្លួន ពី ការទទួល ខុសត្រូវបាននោះឡើយ នៅចំពោះមុខ ប្រជាពលរដ្ឋ និង ប្រវត្តិ សាស្ត្រជាតិ ព្រោះ ទោះបី ប្រជាជាតិខ្មែរ សព្វថ្ងៃ ត្រូវគេលួចប្លន់ និង មាក់ងាយដល់កិត្តិយស តែ នៅសល់ មនុស្សជាតិខ្មែរ ដែល នៅអាចរក្សា នៅក្នុង ដួងចិត្តដដែល នូវព្រលឹងជាតិខ្មែរ ជា អ្នកតស៊ូប្រឆាំងនឹង អកុសល។ ដែលមានន័យច្បាស់ថា ការ តស៊ូ មិនមែន ជា កិច្ចការ នៃ អន្តរជាតិ និង បដិវត្តន៍ពណ៌ អ្វី ឡើយ វាគឺជា កិច្ចការ របស់ **បដិវត្តន៍** នៃប្រជាពលរដ្ឋខ្មែរ ជា ការទទួលខុសត្រូវ លើជោគវាសនាខ្លួនឯង ដ្បិតនៅក្នុង កាយ និងចិត្ត របស់លោក, លោករងទុក្ខក្រៃលែង។